# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ កុយ ស្រួយ ភេទប្រុស អាយុ៥៨ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ “យោធា”
## ស្រុកកំណើតនៅភូមិក្រាំងចេក ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
## រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០១:០១:០៧
## ២៩ទំព័រ

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី១៩ខែ១២ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ស្រួយ: បាទ ។

វណ្ណៈ: ខ្ញុំមកដល់ភូមិឃុំពូចង់ដឹងរឿងរ៉ាវដែលទាក់ទងហ្នឹងសម័យកាលដែលពូធ្លាប់ឆ្លងកាត់កន្លងមករហូតពូបានមករស់នៅតាមជាយដែន ខេត្តឧត្តរមានជ័យនេះ ចឹងបទសម្ភាសខ្ញុំជាមួយពូហ្នឹងខ្ញុំអាចយកទៅសរសេរឲ្យកូនក្មេងជំនាន់ក្រោយបានដឹងបានឮពូមិនថាអីទេ ។

ស្រួយ: ខ្ញុំមិនថាអីទេ ។

វណ្ណៈ: ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ស្រួយ: កុយ ស្រួយ ។

វណ្ណៈ: អាយុប៉ុន្មានពូរាល់ថ្ងៃ?

ស្រួយ: អាយុ៥៨ ។

វណ្ណៈ: ប្រពន្ធពូឈ្មោះអី?

ស្រួយ: ខាត់ សឿន ។

វណ្ណៈ: គាត់មានអាយុប៉ុន្មានហើយ?

ស្រួយ: អាយុ៥៧ ។

វណ្ណៈ: ពូមានកូនប៉ុន្មាននាក់រាល់ថ្ងៃ?

ស្រួយ: ខ្ញុំមានកូន៦នាក់ ។

វណ្ណៈ: មានស្រីប៉ុន្មាន?

ស្រួយ: ស្រី៣ប្រុស៣ ។

វណ្ណៈ: សព្វថ្ងៃពូប្រកបមុខរបរអីដែលរាល់ថ្ងៃហ្នឹង?

ស្រួយៈ ខ្ញុំធ្វើស្រែចម្ការហ្នឹង ធ្វើទាហានដែលតែរំសាយទៅហើយ ។

វណ្ណៈ ចឹងឆ្នាប់គេធ្វើទាហានតែគេរំសាយ?

ស្រួយៈ បាទ ។

វណ្ណៈ ភូមិកំណើតពូនៅណាដែរ?

ស្រួយៈ ភូមិកំណើតនៅភូមិក្រាំងចេក ។

វណ្ណៈ ស្រុក?

ស្រួយៈ ឃុំដើមឫស ស្រុកកណ្តាលស្ទឹង ។

វណ្ណៈ ខេត្តកណ្តាលចឹង?

ស្រួយៈ ខេត្តកណ្តាល ។

វណ្ណៈ ចឹងសព្វថ្ងៃភូមិហ្នឹងគេហៅភូមិអី?

ស្រួយៈ ភូមិទួលប្រាសាទ ។

វណ្ណៈ ឃុំ?

ស្រួយៈ ឃុំទំនប់ដាច់ ។

វណ្ណៈ ស្រុក?

ស្រួយៈ ស្រុកត្រពាំងប្រាសាទ ។

វណ្ណៈ ខេត្ត?

ស្រួយៈ ឧត្តរមានជ័យ ។

វណ្ណៈ ពូមានដឹងទេ កាលពីមុនបានគេដាក់ថាឃុំទំនប់ដាច់មានរឿងអីដែរ?

ស្រួយៈ មិនដឹងជាយ៉ាងម៉េច ពីដើមមកខ្ញុំនៅអូរស្វាយនោះ ដល់ហើយជំនាន់ហ្នឹងគេដឹកមកនៅនេះគេដាក់ភូមិទំនប់ដាច់ចឹងទៅ ទំនប់ហ្នឹងមិនដឹងជាគេលើកពេញកាលមិនបានដឹងដែលហ្នឹង ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងឈ្មោះឪពុករបស់ពូគាត់ឈ្មោះអីដែរ?

ស្រួយៈ ឃួង ប៊ុន ។

វណ្ណៈ ម្តាយ?

ស្រួយៈ ម្តាយ កុយ ណៃ ។

វណ្ណៈ ចឹងគាត់ទាំងពីរពាល់ថ្ងៃនៅរស់ដែរ?

ស្រួយៈ ស្លាប់អស់ហើយ ។

វណ្ណៈ ស្លាប់តាំងជំនាន់ណាទៅ?

ស្រួយៈ ស្លាប់មិនដឹងជាជំនាន់ណាបើខ្ញុំចូលព្រៃបាត់ហើយ ចូលតាំងពីឆ្នាំ៧៣មកម្លេះ ។

វណ្ណៈ ចឹងបងប្អូនពូមានប៉ុន្មាននាក់ដែរ?

ស្រួយៈ បងប្អូនខ្ញុំមានសរុប៩នាក់នោះ ។

វណ្ណៈ ទី១ ឈ្មោះអី?

ស្រួយៈ ឈ្មោះ គង់ ។

វណ្ណៈ ទី២?

ស្រួយៈ ទី២ ស្រៀង ។

វណ្ណៈ ទី៣?

ស្រួយៈ ទី៣ ឪលី ។

វណ្ណៈ ទី៤?

ស្រួយៈ ទី៤ខ្ញុំ ។

វណ្ណៈ ទី៥?

ស្រួយៈ ទី៥ ស្រ៊ី ។

វណ្ណៈ ទី៦?

ស្រួយៈ ទី៦ស្រ៊ុយ ។

វណ្ណៈ ទី៧?

ស្រួយៈ ទី៧សុំ ។

វណ្ណៈ ទី៨?

ស្រួយៈ ទី៨ ញ៉ៅ ហៅ គីម ឡេង ។

វណ្ណៈ ទី៩?

ស្រួយៈ ទី៩ សេង ឡុង ។

វណ្ណៈ ចឹង៩នាក់មានស្រីប៉ុន្មានប្រុសប៉ុន្មាន?

ស្រួយៈ ស្រី៣ប្រុស៦ ។

វណ្ណៈ ចឹងសព្វថ្ងៃហ្នឹងនៅរស់ប៉ុន្មាននាក់ដែរ?

ស្រួយៈ នៅរស់៧នាក់ ស្លាប់ពីរ ។

វណ្ណៈ ចឹង៧នាក់ហ្នឹងមករស់នៅជាយដែនដែលឬមួយនៅស្រុកកំណើតនោះ?

ស្រួយៈ នៅស្រុកកំណើតនោះ នៅស្រុកកំណើត៤នាក់ នៅភ្នំពេញពីរនាក់ ។

វណ្ណៈ ចឹងមាននៅណាទៀត?

ស្រួយៈ មាននៅគេហៅថ្មដា បែកចាន ខេត្តកណ្ដាលយើងហ្នឹង ។

វណ្ណៈ ចឹងមកនៅនេះតែពូទេ?

ស្រួយៈ បាទ! នៅនេះតែខ្ញុំនេះ ។

វណ្ណៈ ចឹងពូកាលពីតូចរៀនសូត្របានត្រឹមណាដែរ?

ស្រួយៈ ខ្ញុំអត់បានរៀនផងរៀនបានត្រឹមថ្នាក់ទី១២"ចាស់" ជំនាន់ហ្នឹង ។

វណ្ណៈ ចឹងលោកពូចេះមើលអក្សរដែលរាល់ថ្ងៃ?

ស្រួយៈ ខ្ញុំមិនចេះទេ ចេះបានតិចៗប្រកប ។

វណ្ណៈ ចឹងយ៉ាងម៉េចបានពូរៀនបានត្រឹមថ្នាក់ទី១២ចឹង?

ស្រួយៈ ជំនាន់ខ្មែរក្រហមគេចូលស្រុក ។

វណ្ណៈ ចឹងសម័យរដ្ឋប្រហារឆ្នាំ១៩៧០ហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងពូរៀនបានតែបន្តិចមានរដ្ឋប្រហារចឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងឈប់ដោយសារកើតមានរដ្ឋប្រហារហ្នឹង?

ស្រួយៈ ហ្នឹងហើយគ្រូអត់ហ៊ានមកបង្រៀន ។

វណ្ណៈ ចឹងឆ្នាំ១៩៧០មានរដ្ឋប្រហារគ្រូមិនហ៊ានមកបង្រៀន ចឹងនៅក្នុងឆ្នាំ១៩៧០-៧១-៧២ អីហ្នឹង ពូនៅផ្ទះឬមួយយ៉ាងម៉េច?

ស្រួយៈ ឆ្នាំ៧១-៧២នៅផ្ទះ ។

វណ្ណៈ ចឹងនៅផ្ទះជួយធ្វើការងារឪពុកម្ដាយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងនៅឆ្នាំណាដែលពូបានចូលជាចលនាបដិវត្ត?

ស្រួយៈ ឆ្នាំ១៩៧៣ ។

វណ្ណៈ ចឹងឆ្នាំ១៩៧៣ ពូស្ម័គ្រចិត្តចូលឬមួយគេមកបង្ខំឲ្យចូល?

ស្រួយៈ គេបង្ខំ ។

វណ្ណៈ កាលសម័យហ្នឹងមានគេបង្ខំដែរ?

ស្រួយៈ បាទ! គេបង្ខំឲ្យចូល ខ្ញុំនៅផ្ទះហ្នឹងខ្ញុំមិនចង់ចូលទេ ។

វណ្ណៈ គេអូសទាញយើងឬគេផ្គុងយើង?

ស្រួយៈ អត់មានផ្គុងទេ គ្រាន់អូសទាញ គ្រាន់ថាបើអ្នកណានៅស្រុកនៅភូមិគេមិនទាន់ទទួលស្គាល់ ប៉ុណ្ណោះឯង មិនទទួលស្គាល់យុវជនយុវនារីអីចឹង ។

វណ្ណៈ ចឹងពូកាលហ្នឹងមានចិត្តចង់ទៅឬគ្មានចិត្តចង់ទៅ?

ស្រួយៈ ចិត្តមិនចង់ចេញពីផ្ទះទេ ។

វណ្ណៈ ពីណាមកអូសទាញពូឈ្មោះអីដែលកាលហ្នឹង?

ស្រួយៈ ខាងឃុំហ្នឹង ។

វណ្ណៈ ឃុំហ្នឹងមានស្គាល់ឈ្មោះ គាត់ទេ?

ស្រួយៈ ឈ្មោះតាឃុន ។

វណ្ណៈ ចឹងកាលឆ្នាំ១៩៧៣ កាលហ្នឹងមិនទាន់គឹងតែងប៉ុន្មានដែលបើយើងមិនទៅក៏គេមិនធ្វើអីយើងដែរ?

ស្រួយៈ បាទ ។

វណ្ណៈ តែគេថា បើយើងមិនទៅគេមិនទទួលខុសត្រូវយ៉ាងម៉េច?

ស្រួយៈ បាទ!ជំនាន់ហ្នឹងបើសិនយើងមិនទៅ គេអត់មានគ្រប់គ្រង គេអត់មានគិតពីម៉ែឪទេ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៣ហ្នឹង នៅស្រុកកណ្ដាលស្ទឹងហ្នឹងខាង លន់ នល់ ចូលអត់ដល់ឬយ៉ាងម៉េចកាលហ្នឹង?

ស្រួយៈ ខាងលន់ នល់ ចូលដល់ម្ដងៗ ។

វណ្ណៈ ចឹងនៅហ្នឹងពីឆ្នាំ១៩៧០-៧៣ហ្នឹងខាងខ្មែរក្រហមចេញចូលតែម្ដង?

ស្រួយៈ បាទ ។

វណ្ណៈ មានឃុំមានអីតែម្ដង?

ស្រួយៈ បាទ!ទាហាន លន់ នល់ មានចេញចូលតាមហ្នឹងដែរ ចេញចូលមួយចេញមួយចូលចឹងទៅណា ។

វណ្ណៈ បាទ ។

ស្រួយៈ ប្រទាញប្រទង់គ្នា ។

វណ្ណៈ ចឹងតាំងឆ្នាំ១៩៧០ដល់៧៣ហ្នឹងមានការទម្លាក់គ្រាប់បែកអីយ៉ាងម៉េចដែរ?

ស្រួយៈ មិនទាន់មានទម្លាក់ទេ ឆ្នាំ៧២-៧៣ហ្នឹង មិនទាន់ទម្លាក់ទេខាងស្រុកខ្ញុំ ។

វណ្ណៈ បាទ!ចឹងដល់ឆ្នាំ៧០ប៉ុន្មានបានមានទម្លាក់?

ស្រួយៈ បានមកឆ្នាំ៧៣-៧៤ហ្នឹងបានមកទម្លាក់គេចចេញពីភូមិអស់ ។

វណ្ណៈ ចឹងឆ្នាំ៧១-៧២នៅទេ?

ស្រួយៈ នៅទេ ។

វណ្ណៈ ចឹង៧៣-៧៤បានមកទម្លាក់?

ស្រួយៈ បាទ!ឆ្នាំ៧១-៧២ នៅក្នុងភូមិហ្នឹងនៅឡើងទេ តែគ្រាប់ផ្លោង ផ្លោងចូលហើយ តែយន្តហោះមិនទាន់មានទម្លាក់ទេ ។

វណ្ណៈ ចឹងកាលផ្លោងចូលចឹងមានគ្រោះថ្នាក់ទេ?

ស្រួយៈ អត់មាន ។

វណ្ណៈ ចឹងកាលដែលពូបានចូលបដិវត្តហ្នឹង កាលពូចូលភ្លាមនៅត្រឹមឃុំឬឡើងដល់ស្រុក?

ស្រួយៈ ចូលដល់ស្រុកបណ្ដោយ ។

វណ្ណៈ ចឹងយោធាស្រុក?

ស្រួយៈ បាទ! យោធាស្រុក ។

វណ្ណៈ កាលចូលជាមួយពូហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

ស្រួយៈ ជំនាន់ខ្ញុំហ្នឹងចូលបានបីបួនប្រាំនាក់ហ្នឹងពួកខ្ញុំ ។

វណ្ណៈ ចឹងទៅដល់ស្រុកបានមានគ្នាច្រើន?

ស្រួយៈ បាទ!ដល់ស្រុកមានគ្នាច្រើន ។

វណ្ណៈ ប្រធានយោធាស្រុកពីណាគេ កាលហ្នឹង?

ស្រួយៈ ឈ្មោះ តាម៉ុន ។

វណ្ណៈ ឥឡូវគាត់នៅរស់ទេ?

ស្រួយៈ មិនដឹងជាយ៉ាងម៉េចមិនដឹងផងឥឡូវហ្នឹង តាំងពីឆ្នាំ១៩៧៥ខ្ញុំគេបញ្ជូនមកទ័ពស្រួចមក ។

វណ្ណៈ ចឹងពូនៅទ័ពស្រុកហ្នឹងរយៈពេលប៉ុន្មានដែលបានគេបញ្ជូនទៅមុខទៀត?

ស្រួយៈ ខ្ញុំនៅរយៈពេលឆ្នាំ៧៣រហូតដល់៧៥ គេបញ្ជូនមកទ័ពស្រួច ។

វណ្ណៈ ចឹងកាលពូនៅយោធាស្រុកហ្នឹងគេឲ្យពូធ្វើអីខ្លះកាលហ្នឹង?

ស្រួយៈ ខ្ញុំអត់មានធ្វើអីផងគេឲ្យធ្វើស្រែធ្វើចម្ការអី ជាមួយនារីៗ ។

វណ្ណៈ តែកាលសម័យឆ្នាំ៧៣-៧៤ហ្នឹងគឺជាសម័យវាយប្រយុទ្ធសកម្មជាមួយទាហាន លន់ នល់ ហើយ ទាល់ឈ្នះបានខាងទ័ពហ្នឹងធ្វើស្រែវិញ?

ស្រួយៈ អត់ទេ ជំនាន់ហ្នឹងក៏នៅធ្វើស្រែដែរ ។

វណ្ណៈ ចឹងឆ្នាំណាបានពូចូលទ័ពស្រួចនោះ?

ស្រួយៈ ចូលទ័ពស្រួចឆ្នាំ១៩៧៥ហ្នឹង ។

វណ្ណៈ នៅក្នុងកងពលលេខប៉ុន្មាន?

ស្រួយៈ កងពលលេខ១៨ ។

វណ្ណៈ ឆ្នាំ១៩៧៥ហ្នឹង?

ស្រួយៈ  បាទ!៧៥ បែកភ្នំពេញហ្នឹង ។

វណ្ណៈៈ  បែកភ្នំពេញហើយឬមិនទាន់វាយទេ?

ស្រួយៈ  វាយហើយកាលនោះជិតចូលភ្នំពេញហើយ ។

វណ្ណៈៈ  ចឹងខែប៉ុន្មានចូល?

ស្រួយៈ  ចូលខែប៉ុន្មានទេ  ខែ៥ដឹង ។

វណ្ណៈៈ  ខែ៥ឆ្នាំ៧៥ឈ្នះហើយ?

ស្រួយៈ  អូស ។

វណ្ណៈៈ  បើថ្ងៃទី១៧មេសា  ខែ៤ខែចូលឆ្នាំ  ខ្មែរក្រហមវាយទីក្រុងភ្នំពេញបានហើយ?

ស្រួយៈ  បាទ!ចូលបានប៉ុន្មានខែទេ  បីខែអី ។

វណ្ណៈៈ  ឈ្នះភ្នំពេញ?

ស្រួយៈ  បាទ ។

វណ្ណៈៈ  ចឹងប្រហែលជាចុងឆ្នាំ៧៤អីហ្នឹង?

ស្រួយៈ  បាទ!ចុង៧៤ហ្នឹងហើយ ។

វណ្ណៈៈ  យោធាយ៉ាងម៉េច  យោធាទ័ពពិសេស?

ស្រួយៈ  បាទ!ទ័ពស្រួចតែម្ដង ។

វណ្ណៈៈ  កាលហ្នឹងនៅកងពល១៤?

ស្រួយៈ  ហ្នឹងហើយ ។

វណ្ណៈៈ  ប្រធានកងពលពីណាគេ?

ស្រួយៈ  ប្រធានកងពល០៥ហ្នឹង ។

វណ្ណៈៈ  ០៥តាសារឿនឬតាសាន?

ស្រួយៈ  តាសារឿន  តាសានហ្នឹងអនុគាត់ ។

វណ្ណៈៈ  ចឹងកាលពីមុនតាសានអនុតាសារឿនទេ?

ស្រួយៈ  បាទ ។

វណ្ណៈៈ  ក្រោយមកឈ្នះភ្នំពេញបានឡើង?

ស្រួយៈ  ក្រោយមកឈ្នះភ្នំពេញបានគាត់ឡើងកងពល៩២០ បានគាត់ប្រធាន ។

វណ្ណៈៈ  ចឹងមុខព្រួញពូចូលខាងទ័ពស្រួចឡើងវាយជាមួយទាហាន  លន់  នល់?

ស្រួយៈ  បាទ ។

វណ្ណៈៈ  ចឹងពូវាយតាមច្រកណា  ពេលឡើងទៅភ្នំពេញ?

ស្រួយៈ ខ្ញុំអត់មានបានឡើងវាយទេ ឲ្យខ្ញុំដញ្ជូនបាយ ។

វណ្ណៈ ចឹងពូនៅខាងដញ្ជូនបាយឲ្យទ័ពវិញ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងដញ្ជូនបាយនិងបញ្ជូនអ្នករបួសមកវិញ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងសង្គ្រាមកាលហ្នឹងពូមានដឹងថាមានស្លាប់ច្រើនទេ?

ស្រួយៈ ស្លាប់ច្រើនហ្នឹងហើយ ។

វណ្ណៈ ពូមានភ័យខ្លាចទេ កាលហ្នឹង?

ស្រួយៈ និយាយមិនខ្លាចយ៉ាងម៉េច តែមិនថាគេចទៅត្រង់ណា ។

វណ្ណៈ ពូមានចង់មកផ្ទះវិញទេកាលហ្នឹង?

ស្រួយៈ ចង់ៗណាស់ហើយ ។

វណ្ណៈ ចឹងមកអត់បាន?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងនៅដញ្ជូនបាយរហូតដល់បែកឆ្នាំ៧៥ឬបានឡើងវាយដែរ?

ស្រួយៈ ដញ្ជូនបាយរហូតដល់បែកឆ្នាំ៧៥ ។

វណ្ណៈ ចឹងពូអត់មានបានកាន់កាំភ្លើងឡើងវាយទេចឹង?

ស្រួយៈ អត់ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៥ពូមានបានចូលដល់ភ្នំពេញទេ ពេលឈ្នះហ្នឹង?

ស្រួយៈ បាន ។

វណ្ណៈ ចូលដល់ភ្នំពេញនៅម៉ោងប៉ុន្មាន?

ស្រួយៈ ខ្ញុំចូលក្រោយគេ ទ័ពស្រួចគេវាយហ្នឹងគេចូលមុនខ្ញុំ បែកបីថ្ងៃបួនថ្ងៃបានខ្ញុំបានចូលភ្នំពេញ ។

វណ្ណៈ ចឹងពេលរយៈពេលបីបួនថ្ងៃបានពូចូលដល់ភ្នំពេញហ្នឹងពូមានឃើញគេជម្លៀសប្រជាជនចេញទេ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងប្រជាជនជម្លៀសចេញហើយពេលហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ពេលប្រជាជនជម្លៀសចេញហ្នឹង ពូមើលទៅឃើញប្រជាជនសប្បាយចិត្តឬមួយមានបារម្មណ៍ពួកគាត់ដែលចេញទៅហ្នឹង?

ស្រួយៈ គាត់អត់មានសប្បាយចិត្ត ពួកគាត់បារម្មណ៍ ។

វណ្ណៈ ចឹងគាត់មានការភ័យខ្លាច?

ស្រួយៈ បាទ!មិនដឹងគេជម្លៀសឲ្យទៅខាងណាអីខាងណា ។

វណ្ណៈ ចឹងពូចូលទៅដល់ភ្នំពេញហើយ ពូនៅកន្លែងណា?

ស្រួយៈ ខ្ញុំនៅតាមផ្ទះគេ ។

វណ្ណៈ នៅតាមផ្ទះតែនៅភ្នំពេញហ្នឹង វាមានដូចនៅម្តុំផ្សារថ្មី ខ្លះនៅទួលគោក ខ្លះនៅទួលទំពូង?

ស្រួយៈ ខ្ញុំនៅផ្សារដេប៉ូ ។

វណ្ណៈ ចឹងកាលនៅផ្សារដេប៉ូហ្នឹងពូនៅធ្វើអី នៅរៀបចំផ្ទះឬមួយនៅធ្វើអីដែរ?

ស្រួយៈ បាទ!រៀបចំផ្ទះ ។

វណ្ណៈ ចឹងមានធ្វើអីទៀតដែលពូ?

ស្រួយៈ មានធ្វើអីគ្រាន់ដើរឲ្យរៀបចំផ្ទះ រៀបរាល់ថ្ងៃរៀបរើៗហ្នឹង អ្នករៀបៗអ្នករើៗ ។

វណ្ណៈ ចឹងកាលនៅភ្នំពេញហ្នឹងនៅក្នុងកងពល១៨ដដែលឬមួយមានការផ្លាស់ប្តូរកងពលហើយ?

ស្រួយៈ អត់មានផ្លាស់ប្តូរទេ រហូតមកដល់សព្វថ្ងៃនេះឯង ។

វណ្ណៈ ចឹងចាំមើលខ្ញុំនិយាយ ពូនៅភ្នំពេញហ្នឹង ក្រោយពីរៀបចំផ្ទះហើយ ត្រូវអង្គការបញ្ជូនទៅខេត្តទៀតដែលឬមួយពូនៅភ្នំពេញរហូតដល់ឆ្នាំ៧៩?

ស្រួយៈ ខ្ញុំទៅខាងខេត្តរតនៈគិរី ។

វណ្ណៈ ខេត្តរតនៈគិរី?

ស្រួយៈ បាទ ។

វណ្ណៈ ឆ្នាំណាពូចេញមក?

ស្រួយៈ ចេញឆ្នាំ៧៥ហ្នឹង ។

វណ្ណៈ ចឹងមកនៅជាមួយប្រធានកងពលពីណា?

ស្រួយៈ តា០៥ដដែលហ្នឹង ។

វណ្ណៈ ចឹងកងពលលេខប៉ុន្មាន?

ស្រួយៈ គ្រាន់ដូរតែលេខទេ លេខកងពល៨០១ប៉ុណ្ណឹងឯង ដូរតែលេខទេ អ្នកដឹកនាំដដែល ។

វណ្ណៈ ចឹងតា សូ សារឿន ដដែល?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ តាសូរ សារឿន ហ្នឹងអនុគាត់ពីណាគេ?

ស្រួយៈ អនុគាត់ហ្នឹងមុនតាសានហ្នឹងដែរតា០៦តាសានហ្នឹង ។

វណ្ណៈ	ចឹងតាសានកាលវាយ  ពេលឆ្នាំ៧៥ហើយមានការបែងចែកឲ្យទៅកាន់កងពល?
ស្រួយៈ	អត់ទេ ។
វណ្ណៈ	តាសាន  គាត់ទៅកាន់កងពល៩២០?
ស្រួយៈ	ខ្ញុំអត់សូវដឹងដែរ  ខ្ញុំដឹងថាម្នាក់ហ្នឹងឯង ។
វណ្ណៈ	ចឹងកាលពីចេញពីភ្នំពេញហ្នឹងពូជិះអីទៅ?
ស្រួយៈ	ជិះឡាន ។
វណ្ណៈ	ជិះឡានទៅដល់ណា?
ស្រួយៈ	ជិះឡានទៅដល់ស្ទឹងត្រែង ។
វណ្ណៈ	ចឹង?
ស្រួយៈ	បាទ ។
វណ្ណៈ	តែអ្នកខ្លះនិយាយថា  ជិះទូកទៅដល់ខេត្តក្រចេះ  ចេញពីក្រចេះទៅទៀត?
ស្រួយៈ	បាទ!ចេញពីភ្នំពេញទៅជិះកាណូតទៅដល់ឡើងក្រចេះ ។
វណ្ណៈ	ចឹងទេ?
ស្រួយៈ	បាទ ។
វណ្ណៈ	ចឹងខ្ញុំស្មានជិះពីភ្នំពេញទៅ?
ស្រួយៈ	អត់ទេ ។
វណ្ណៈ	ខ្ញុំឮពូនិយាយមិញថាជិះឡានរហូត  ចឹងស្មានជិះពីភ្នំពេញទៅ  ចឹងដូចគ្នាទេ?
ស្រួយៈ	បាទ!ជិះកាណូតឡើងត្រឹមក្រចេះ ។
វណ្ណៈ	ចឹងកាលពូទៅមានគ្នាដល់រាប់ពាន់នាក់ទេ?
ស្រួយៈ	បាទ!រាប់ពាន់នាក់ហ្នឹង ។
វណ្ណៈ	ចឹងដល់ក្រចេះសម្រាកបានប៉ុន្មានថ្ងៃបានចេញដល់ខេត្តរតនៈគិរីទៀត?
ស្រួយៈ	នៅបានប្រហែលជាកន្លះខែ ។
វណ្ណៈ	ចឹងកាលចេញពីក្រចេះទៅយើងជិះឡានទៀតឬមួយជិះអី?
ស្រួយៈ	ជិះឡានដល់ស្ទឹងត្រែង ។
វណ្ណៈ	ចឹងទៅដល់ខេត្តស្ទឹងត្រែងជិះអីទៀតទៅពូ?
ស្រួយៈ	មិនដល់ស្រុកអីទេ ។
វណ្ណៈ	ស្រុកវើនសៃ?
ស្រួយៈ	ស្រុកវើនសៃ  មិនដឹងជាស្រុកអីស្រុកវើនសៃដឹង ។

វណ្ណៈ ស្រុករនសែខ្វះទៅស្រុកថ្ឡាបរិវ៉ាត់?

ស្រួយៈ អត់ទេ ថ្ឡាបរិវ៉ាត់ស៊ីងត្រែង ។

វណ្ណៈ ចឹងស៊ីងត្រែងទេ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងទៅខេត្តរតនៈគិរីស្រុករនសែ?

ស្រួយៈ បាទ!រនសែ ។

វណ្ណៈ ចឹងចេញពីស៊ីងត្រែងជិះទូកទៀត?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងយ៉ាងម៉េចបានជាមិនជិះឡាន?

ស្រួយៈ មិនដឹងជាយ៉ាងម៉េចជំនាន់ហ្នឹង ។

វណ្ណៈ ចឹងទៅដល់ហ្នឹងគេឲ្យពូទៅការពារនៅព្រំដែនឬគេឲ្យពូទៅធ្វើស្រែឬទៅធ្វើពេទ្យឬមួយយ៉ាងម៉េច ពូ?

ស្រួយៈ កាលទៅដល់ដំបូងទៅកាប់ឈើកាប់ព្រៃ វាទដីធ្វើភូមិហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងកាប់ធ្វើបន្ទាយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលទៅដល់ហ្នឹងមានឈឺគ្រុនចាញ់ច្រើនដែលឬមួយយ៉ាងម៉េច?

ស្រួយៈ មានគ្រុនចាញ់ច្រើនណាស់ទៅហ្នឹង គ្រុនចាញ់ស្លាប់ឡើងច្រើនណាស់ ។

វណ្ណៈ ចឹងស្លាប់ច្រើន?

ស្រួយៈ បាទ ។

វណ្ណៈ ពូឈឺដែលកាលហ្នឹង?

ស្រួយៈ ខ្ញុំឈឺនៅតែពេទ្យហ្នឹង គ្មានបានការស្ការអីទេខ្ញុំនោះ ។

វណ្ណៈ សំណាងដែលចឹង?

ស្រួយៈ បាទ ។

វណ្ណៈ ខ្វះឈឺស្លាប់?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូឈឺគេបញ្ជូនមកពេទ្យដល់ជាគេបញ្ជូនទៅមុខវិញ?

ស្រួយៈ អត់ទេ គេបញ្ជូនមកកន្លែងវិញដដែល ។

វណ្ណៈ ចឹងកាលពូទៅដល់ខេត្តរតនៈគិរីហ្នឹង ពូមានទៅការពារព្រំដែនទេ?

ស្រួយៈ អត់មានទេ ។

វណ្ណៈ ចឹងនៅក្នុងបន្ទាយធ្វើស្រែ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងតាសា រឿន គាត់មានចុះទៅផ្ទាល់ទេ?

ស្រួយៈ គាត់អត់មានចុះទៅដែលហ្នឹង គាត់នៅតែកន្លែងគាត់ហ្នឹង តាមរយៈមេៗតៗគ្នាទៀតហ្នឹង ។

វណ្ណៈ នៅហ្នឹងគេហៅតំបន់ប៉ុន្មានភូមិភាគអីដែរ?

ស្រួយៈ ទេ មិនសូវស្គាល់ផងកាលហ្នឹង មិនដឹងជាតំបន់មិនដឹងភូមិភាគស្អីទេកន្លែងហ្នឹង ខ្ញុំមិនស្គាល់ដែលកាលហ្នឹងនោះ ។

វណ្ណៈ ដឹងថារតនៈគិរី?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលពូនៅខេត្តកណ្តាលពូមានដឹងថាតំបន់អីដែរ?

ស្រួយៈ ខេត្តកណ្តាលដឹងថាតំបន់២៥ ។

វណ្ណៈ ភូមិភាគអី?

ស្រួយៈ ទេ រឿងភូមិភាគមិនដឹងថាភូមិភាគអីដែលហ្នឹង តែដឹងថាតំបន់២៥ហ្នឹងឬតំបន់១៥ទេកាលហ្នឹង ។

វណ្ណៈ ចឹងមកដល់ខេត្តរតនៈគិរីស្រុកវើនសៃពូមិនបានដឹងថាតំបន់ប៉ុន្មានភូមិភាគប៉ុន្មានទេ?

ស្រួយៈ អត់ដឹង ។

វណ្ណៈ ចឹងគណៈតំបន់មានស្គាល់ទេ?

ស្រួយៈ អូ! ស្រាច់ ។

វណ្ណៈ ចឹងស្គាល់តែប្រធានកងពល?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងប្រធានអនុសេនាធំអនុសេតូចអី?

ស្រួយៈ ប្រធានអនុសេនាធំអនុសេនាតូចស្គាល់ ។

វណ្ណៈ អនុសេនាធំឈ្មោះ?

ស្រួយៈ ឈ្មោះ សឿន ។

វណ្ណៈ អនុសេនាតូច?

ស្រួយៈ ឈ្មោះ ខន ។

វណ្ណៈ ចឹងកាលហ្នឹងមួយកងពលពូមានដឹងថាមានប៉ុន្មាននាក់ដែរ កាលហ្នឹង?

ស្រួយៈ ខ្ញុំមិនដឹងទេ ។

វណ្ណៈ ចឹងមួយវរសេនាធំមានប៉ុន្មាននាក់?

ស្រួយៈ វរសេនាធំក៏មិនសូវដឹង ។

វណ្ណៈ ចឹងកាលហ្នឹងពូមានតួនាទីអីដែរ?

ស្រួយៈ អត់ខ្ញុំយុវជន ។

វណ្ណៈ ចឹងភាគច្រើនពូធ្វើស្រែដាំបាយចុងភៅ?

ស្រួយៈ បាទ! ធ្វើស្រែដាំបាយរឿងដាំបាយខ្ញុំហើយ ។

វណ្ណៈ ចឹងរយៈពេលបីឆ្នាំកាលពូទៅដល់ខេត្តតរនៈគិរីហ្នឹងមានដែលឃើញគេចាប់មនុស្សទេ?

ស្រួយៈ អត់មានឃើញទេ ។

វណ្ណៈ ចឹងកងទ័ពហ្នឹងនៅដាច់ពីប្រជាជនទេ អត់នៅជាមួយប្រជាជនទេ?

ស្រួយៈ អត់ទេ នៅដាច់ ។

វណ្ណៈ ចឹងយើងមិនដែលឃើញប្រជាជនយ៉ាងម៉េចទេ?

ស្រួយៈ បាទ!មិនដែលឃើញទេ ។

វណ្ណៈ ចឹងកាលនៅហ្នឹងមានដែលវាយជាមួយលាវជាមួយវៀតណាមអីទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ ចឹងពូនៅសមរភូមិក្រោយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងនៅខាងមុខអីពូអត់មានដឹងរឿងទេ? .

ស្រួយៈ បាទ!ខ្ញុំមិនបានដឹងទេ ។

វណ្ណៈ ចឹងពេលដាច់វៀតណាមចូលឆ្នាំ១៩៧៩ ពេលវៀតណាមចូលពូមានបំណងរត់មកផ្ទះវិញឬមួយយ៉ាងម៉េចកាលហ្នឹង?

ស្រួយៈ មានបំណងចង់រត់មកផ្ទះតែមិនដឹងជារត់តាមច្រកណា ។

វណ្ណៈ កាលហ្នឹងពូរៀបការហើយនៅ?

ស្រួយៈ នៅមិនដឹងរត់តាមច្រកណាម្យ៉ាងមិនដឹងស្រុកភូមិ មិនដឹងផ្ទះសំបែងមិនដឹងបងប្អូនដល់ណាមកណា ម៉ែឪយ៉ាងម៉េចម៉ាអត់មានដឹងផង ។

វណ្ណៈ ចឹងឆ្នាំ១៩៧៩ហ្នឹងយើងដឹងទាំងអស់គ្នាថាប្រទេសយើងមានការប្រែប្រួលហើយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកម្លាំងរបស់ពួឈរជើងនៅខាងខេត្តរតនៈគិរីឬមួយដើរកាត់ព្រៃចល័តមកខាងជាយដែនឬមួយយ៉ាងម៉េចកាលហ្នឹង?

ស្រួយៈ ចល័តមកខាងភ្នំដងរែកនេះឯង ។

វណ្ណៈ ចឹងកម្លាំងតាសា រឿន គាត់ជាអ្នកដឹកនាំមក?

ស្រួយៈ តាធី ។

វណ្ណៈ តាធី ហ្នឹងគាត់មានឋានៈធ្វើអី?

ស្រួយៈ គាត់ប្រធានវរៈសេនាធំ ។

វណ្ណៈ ចឹងសឿនហ្នឹងវរសេនាធំដែរ?

ស្រួយៈ សឿន ហ្នឹងវរសេនាតូចទេ ។

វណ្ណៈ ចឹងខន?

ស្រួយៈ ខន ហ្នឹងអនុសេនាតូច ។

វណ្ណៈ ចឹងពេលតាធី ដឹកនាំមកតាមផ្លូវមានជួបបញ្ហាអីខ្លះដែរ?

ស្រួយៈ អត់មានជួបទេ ។

វណ្ណៈ អត់មានជួបខាងវៀតណាមទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ ចឹងពួរត់មកដល់ជាយដែននៅឆ្នាំណាដែរ?

ស្រួយៈ ឆ្នាំ១៩៨២ ។

វណ្ណៈ នៅក្នុងព្រៃយូរម្ល៉េះ?

ស្រួយៈ បាទ! នៅក្នុងពីរឆ្នាំ ។

វណ្ណៈ មានអ្នកខ្លះរត់ទៅដល់ឆ្នាំ៨០-៧៩អីទៅដល់១០០១-១០០២-១០០៣អីចឹង?

ស្រួយៈ បាទ!ខ្ញុំនៅ១០០១ហ្នឹងហើយ ។

វណ្ណៈ ចឹងពួរត់ទៅនៅខាងណា?

ស្រួយៈ នេះខ្ញុំរត់ពីរតនៈគិរីមកនៅ១០០១ហ្នឹងហើយ ខ្ញុំឆ្លងទន្លេមក១០០១ហ្នឹង ។

វណ្ណៈ តែពួរត់ដល់ទៅពីរឆ្នាំយូរណាស់?

ស្រួយៈ ចុះពួននៅរតនៈគិរីហ្នឹងរហូត ។

វណ្ណៈ ចឹងគេចនៅព្រៃចឹងមានអីហូបមានចលនាមានខ្សែរយៈអីគេផ្តល់ឲ្យ?

ស្រួយៈ ហូបមើមឈើមើមព្រៃហូបក្តួច មានដំឡូង ។

វណ្ណៈ ចឹងមានអ្នកស្លាប់បន្តទៀតហើយចឹង?

ស្រួយៈ មានមួយៗ ។

វណ្ណៈ ចឹងឆ្នាំណាដែលពូមកដល់១០០១?

ស្រួយៈ ឆ្នាំ៨១-៨២ ។

វណ្ណៈ ចឹងមកដល់១០០១ពូមានឃើញពីណាមុនគេអ្នកដឹកនាំ?

ស្រួយៈ អ្នកដឹកនាំតាសា រឿន ហ្នឹងហើយ ។

វណ្ណៈ មកដល់ជួបគាត់នៅហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ជួបគាត់នៅហ្នឹងគាត់រៀបកម្លាំងឡើងវាយម្ដងទៀតឬមួយយ៉ាងម៉េចនៅហ្នឹង?

ស្រួយៈ តែកម្លាំងឡើងវាយខ្ញុំមិនសូវដឹងទេ តែខ្ញុំដឹងថាមកដល់រៀបចំប្រជាជនឲ្យនៅតាមហ្នឹងតាមតំបន់តាមទន្លេល្ពៅ ។

វណ្ណៈ ចឹង១០០១នៅទន្លេល្ពៅ ចឹង១០០១ប្រកទន្លេល្ពៅហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងតាមពិតនៅ១០០១តាសុន សេន គាត់គ្រប់គ្រងលើតាសា រឿន ទៀតឬមួយយ៉ាងម៉េច?

ស្រួយៈ បាទ!តាសុន សេន ឮតែឈ្មោះទេ ខ្ញុំមិនដែលឃើញច្បាស់ទេ ។

វណ្ណៈ ចឹងអត់មានជួបតាម៉ុកទេជួបតាសា រឿន អីវិញទេ?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលហ្នឹងមកដល់១០០១ហ្នឹងពូរៀបការហើយនៅ?

ស្រួយៈ នៅទេ ។

វណ្ណៈ ចឹងពូកាន់កាំភ្លើងហើយពេលហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងគេបញ្ជូនពូទៅសមរភូមិមុខវិញដែរ?

ស្រួយៈ អត់ទេ ខ្ញុំសុខភាពអត់បាន អត់មានបញ្ជូនទៅណាខ្ញុំនៅតែក្រោយហ្នឹង ។

វណ្ណៈ ចឹងមាននៅ១០០១ហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងអត់មានចូលសមរភូមិទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ ចឹងពូនៅ១០០១គេឲ្យពូធ្វើអីបើពូនៅក្រោយចឹង?

ស្រួយៈ គ្មានទេ អត់ទេ ។

វណ្ណៈ ចឹងគេអត់មានឲ្យបិតចំរូងអីទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ ចឹងធ្វើអីទៅ?

ស្រួយៈ នៅជាមួយមីងៗហ្នឹង ។

វណ្ណៈ នៅជាមួយមីងៗធ្វើអី?

ស្រួយៈ មីងៗអត់មានធ្វើអីទេ ដេកបើកអង្ករហូបប៉ុណ្ណោះឯង ។

វណ្ណៈ ចឹង?

ស្រួយៈ បាទ!ជំនាន់ហ្នឹងអត់មានធ្វើអីទេ ។

វណ្ណៈ ចឹងកាលនៅ១០០១-១០០២កាលហ្នឹងយើងវាយជាមួយវៀតណាម ឆ្នាំ៨១-៨២ហ្នឹង យើងចាប់ផ្ដើមវាយជាមួយទាហានរដ្ឋាភិបាលនិងជាមួយទាហានវៀតណាម ហើយកាលហ្នឹង ស្រីៗគេឲ្យជញ្ជូនគ្រាប់?

ស្រួយៈ ហ្នឹងហើយគ្រាន់តែជញ្ជូនគ្រាប់ ។

វណ្ណៈ និយាយទៅមានជញ្ជូនគ្រាប់អី បើពូនិយាយថាសម្រាកដេកស៊ីចាំបើកអង្ករចឹងមានលុយណាគេឧបត្ថម្ភឲ្យ?

ស្រួយៈ ចឹងមីងៗអត់មានធ្វើអីទេ ដោយឡែកនារីៗទេជញ្ជូនគ្រាប់ នារីៗទេគេដឹកជញ្ជូន ។

វណ្ណៈ ចឹងអ្នកដែលអត់មានកូនគេឲ្យដឹកជញ្ជូន?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងអ្នកមានកូនហើយគេឲ្យនៅដូចជាជំរុំ ប៉ុន្តែថ្នាក់លើគេបញ្ជាឲ្យយើងអ្នកនៅតាមជំរុំច្រក១០០១ហ្នឹង នៅក្នុងភូមិអីចឹងគេឲ្យធ្វើស្រែអីទៅហើយមានអង្ករគេជួយឧបត្ថម្ភ ជួនកាលគេឲ្យបិតចំរូងខ្លះដែរ?

ស្រួយៈ អត់មានបិតទេ ។

វណ្ណៈ ចឹងនៅ១០០១អត់មានបិតទេ?

ស្រួយៈ បាទ!អត់មានទេ រឿងស្រែក៏អត់មានធ្វើដែរ ។

វណ្ណៈ ចឹងចាំតែទទួលអង្ករតែម្ដង?

ស្រួយៈ ចាំទទួលអង្ករបួនដប់ថ្ងៃបើកៗ ។

វណ្ណៈ ចឹងពូនៅ១០០១ហ្នឹងពូនៅកងពល៨០១ដដែល?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងដោយសារពូអត់មានសុខភាពមិនល្អគេឲ្យពូនៅសមរភូមិក្រោយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងនៅ១០០១ហ្នឹងរយៈពេលប៉ុន្មានបានមានការផ្លាស់ប្ដូរទៀត?

ស្រួយៈ នៅយូរដែលនៅ៤ទៅ៥ឆ្នាំហ្នឹងណា ។

វណ្ណៈ ចឹងនៅហ្នឹង៤ទៅ៥ឆ្នាំពូអត់មានជួយធ្វើអីទេ ជួយដឹកជញ្ជូនខ្លះដែលឬយ៉ាងម៉េច?

ស្រួយៈ អត់ទេ ខ្ញុំអត់មានដឹកជញ្ជូនអីទេ ។

វណ្ណៈ ចឹងកាលហ្នឹងម៉េចបានពូគ្មានបំណងរត់ទៅក្រៅប្រទេស?

ស្រួយៈ មានអីរត់ទៅ ។

វណ្ណៈ ចឹងគេទៅជំរំនោះ គេចេញទៅជំរំទៅមានអង្គការមកយកទៅអាមេរិចទៅអូស្ត្រាលីទៅបារាំងអីនោះ?

ស្រួយៈ កាលហ្នឹងខ្ញុំនៅជំរំតែជំរំហ្នឹងមិនមែនអង្គការគ្រប់គ្រងទេ ជំរំខ្មែរក្រហមគ្រប់គ្រង ។

វណ្ណៈ ចឹងខ្មែរក្រហមគ្រប់គ្រងយើងចេញមិនរួច?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងបើយើងចង់រត់ចេញបានទេ?

ស្រួយៈ រត់ចេញបានកាលនៅជំរំអូរត្រាវកាលនោះ ។

វណ្ណៈ តែមិនហ៊ានរត់?

ស្រួយៈ អីមិនហ៊ានតែខ្ជិលរត់ មិនដឹងថារត់ទៅណា ។

វណ្ណៈ ខ្ញុំជួបច្រើនដែលខ្លះទៅដល់អាមេរិចឥឡូវគេធូរធារដែរ?

ស្រួយៈ បាទ!អ្នកធូរធារគេទៅដល់អាមេរិចអីហ្នឹង យើងមានស្អីទៅ ។

វណ្ណៈ កាលជំនាន់ហ្នឹងក្លាម ៗ ឆ្នាំ៧៩-៨០ គេជួយតែម្ដង យើងរត់ទៅចឹងគេជួយយើងឲ្យទៅតែម្ដងកាលហ្នឹង?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ យើងមិនចាំបាច់មានលុយកាក់ទេ?

ស្រួយៈ ខ្ញុំអត់ដឹងដែលហ្នឹង ។

វណ្ណៈ ចឹងកាលពូនៅ១០០១ក្រោយមកមានបានជួបតាម៉ុក ទៅយកឲ្យមកកន្លែងណាវិញទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ ចឹងពូមានស្គាល់១០០៣-១០០២អីទេ៨០៨អី?

ស្រួយៈ ពុំតែឈ្មោះ តែរឿងស្គាល់អត់មានស្គាល់ទេ គ្រាន់តែពុឈ្មោះ ។

វណ្ណៈ ចឹងពូស្គាល់តែច្រក១០០១ហ្នឹង?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលហ្នឹងពូចេញពី១០០១មិនដឹងឆ្នាំណាទេ?

ស្រួយៈ អត់! មើលចេញ១០០១មានឆ្នាំណាមានតែឆ្នាំ១៩៩០ហ្នឹង ។

វណ្ណៈ ឆ្នាំ១៩៩០ពូមកនៅណា?

ស្រួយៈ ឆ្នាំ១៩៩០គេដឹកចុះមកដីខ្មែរវិញ ។

វណ្ណៈ ចុះមកដល់ដំបូងចុះមកនៅភូមិហ្នឹងឬមួយចុះមកនៅណាឬនៅអូរស្មាយ?

ស្រួយៈ ចុះមកដល់ដំបូងចុះមកនៅអូរស្មាយ ។

វណ្ណៈ ចឹងកាលអូរស្មាយហ្នឹងគេដាក់ឈ្មោះតាំងពីពេលណាមក?

ស្រួយៈ គេអត់មានឈ្មោះ ភូមិទេ គេហៅអូរស្មាយហ្នឹងតែម្តង ។

វណ្ណៈ ចឹងអូរស្មាយចឹងនៅហ្នឹងគេដាក់កងពលប៉ុន្មាន កងពលលេខដូនកាលភូមិមួយខ្លះគេដាក់ថាភូមិ ១០៥ខ្លះដាក់ភូមិ៨៥អីចឹង?

ស្រួយៈ អត់ទេ នៅហ្នឹងគេដាក់ភូមិ៨៩ ។

វណ្ណៈ ចឹងនៅនេះគេដាក់អីវិញ?

ស្រួយៈ នេះគេហៅភូមិទួលប្រាសាទ ខ្លះគេហៅ៨៩ដែរ ។

វណ្ណៈ ចឹងនៅអូរស្មាយ៨៩ដែរ?

ស្រួយៈ បាទ! ហ្នឹងលេខកង ។

វណ្ណៈ ចឹងកងតែមួយចឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងយ៉ាងម៉េចបានជាគេដាក់លេខ៨៩គេចំណាំអីគេ?

ស្រួយៈ មិនដឹងយ៉ាងម៉េចគេថា៨៩ៗកងៗចឹង ។

វណ្ណៈ ចឹងខបមាថាកងពល៩២០ទៅនៅកន្លែងផ្សេង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹង៨០១នៅកន្លែងផ្សេងចឹង?

ស្រួយៈ បាទ! នៅបែកចែកចឹង ។

វណ្ណៈ ចឹងពូមិនមែននៅកងពលពូ ដាន់ណា តាពឹមនៅអន្លង់វែងទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ  ចឹងពូនៅអូរស្វាយហ្នឹងឆ្នាំ៩០ ចឹងពូមានដឹងថាតាម៉ុក ធ្វើផ្លូវចុះពីលើភ្នំមកនៅឆ្នាំណាឆ្នាំ៩០ ដែរឬមួយយ៉ាងម៉េច?

ស្រួយៈ  ផ្លូវជាំហ្នឹង ។

វណ្ណៈ  បាទ ។

ស្រួយៈ  កាលហ្នឹងធ្វើដូចជាក្រោយឆ្នាំ៩០ទេ កាលខ្ញុំចុះមកហ្នឹងផ្លូវយ៉ាប់ ។

វណ្ណៈ  ចុះតាមហ្នឹងដែរ?

ស្រួយៈ  ចុះតាមហ្នឹងឡានដឹកយ៉ាប់ ។

វណ្ណៈ  ចឹងតាមច្រកជាំហ្នឹងមានផ្លូវដែរ?

ស្រួយៈ  ហ្នឹងហើយតាមហ្នឹង តែចុះភ្នំចេះត្រង់ណាចោតគេមិនឲ្យជិះទេ ចុះដើរ ។

វណ្ណៈ  ចឹងពេលចុះមកដល់គេឲ្យនៅអូរស្វាយ?

ស្រួយៈ  បាទ ។

វណ្ណៈ  ចឹងនៅអូរស្វាយហ្នឹងក្រោយមកមានអ៊ុនគាក់ទៀតពូមានដឹងទេ?

ស្រួយៈ  ដឹង គ្រាន់ឮសូរអ៊ុនគាក់ចូលទេ តែមិនដែលឃើញទេ ។

វណ្ណៈ  ចឹងកាលអ៊ុនគាក់ចូលមកពេលបោះឆ្នោតឆ្នាំ៩៣អីពូមានបានបោះទេ?

ស្រួយៈ  អត់ទេ ។

វណ្ណៈ  ចឹងនៅខាងខ្មែរក្រហមមិនបានបោះទេ?

ស្រួយៈ  ហ្នឹងហើយ ។

វណ្ណៈ  តែនៅកន្លែងខ្លះគេបានបោះ?

ស្រួយៈ  បាទ ។

វណ្ណៈ  ខ្លះខាងខ្មែរក្រហមបានបោះដែលបោះឲ្យខាងហ៊ុនស៊ិនប៉ិចកាលហ្នឹង?

ស្រួយៈ  បាទ ។

វណ្ណៈ  ចឹងពូមានដែលឃើញគាត់ទេ?

ស្រួយៈ  អត់ដែលឃើញសោះឃើញតែឈ្មោះទេ ។

វណ្ណៈ  ចឹងក្រោយមកទៀតពូនៅអូរស្វាយរយៈពេលប៉ុន្មានឆ្នាំ?

ស្រួយៈ  នៅរយៈពេលទាល់រដ្ឋាភិបាលផ្តាច់ខ្លួនចូលរដ្ឋាភិបាលហ្នឹង ។

វណ្ណៈ  ចឹងពេលពូចុះមកដល់ហ្នឹង តើមានការវាយដេញពីខាងរដ្ឋាភិបាលប៉ុន្មានដងទៀតបានប្រទេសយើងមានសន្តិភាពនៅរហូតបាន ចឹងកាលហ្នឹងពូចុះមកមានរត់ឡើងទៀតទេ?

ស្រួយៈ  អត់មានរត់ឡើងភ្នំទេ រត់តែខាងក្រោមដីស្មើហ្នឹង ចល័តនៅចល័តមកហ្នឹង ។

វណ្ណៈ	ចឹងអត់មានរត់ឡើងភ្នំទេ?

ស្រួយៈ	អត់មានរត់ឡើងទេ ។

វណ្ណៈ	ចឹងពួកក្បែរៗហ្នឹងស្ងប់កាំភ្លើងចូលទៅវិញ?

ស្រួយៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹងចុះមកដល់ដំបូងមានធ្វើផ្ទះធំៗនៅ?

ស្រួយៈ	អត់ទេ កាប់ឈើធ្វើតូចៗ ផ្ទះធំហើយប៉ុននេះ ។

វណ្ណៈ	ចឹងកាលហ្នឹងធ្វើតូចៗព្រោះមិនដឹងថានៅឋិតថេរអត់?

ស្រួយៈ	បាទ! ធ្វើជំរំមួយជ្រកៗចឹងទៅ ។

វណ្ណៈ	ហើយរបបហូបចុកតាម៉ុក បើកឲ្យទៅ?

ស្រួយៈ	បាទ! របបបើកឲ្យខ្លះ គេឲ្យធ្វើស្រែចម្ការខ្លួនឯងខ្លះហើយ ។

វណ្ណៈ	ចឹងហូបចុកបានគ្រប់គ្រាន់ទេ?

ស្រួយៈ	ហូបចុកគ្រប់គ្រាន់ ។

វណ្ណៈ	ចឹងក្រោយមកទៀតនៅខាងអន្លង់វែងមានរឿងរ៉ាវច្រើន គេចាប់តាប៉ុល ពត កាត់ទោសអីពូមានដឹងទេកាលហ្នឹង?

ស្រួយៈ	ដឹងតែខ្ញុំនៅអូរស្វាយនេះ ។

វណ្ណៈ	អត់មានបានចូលរួមកាត់ទោសអីហ្នឹងគេទេ?

ស្រួយៈ	អត់ទេ ។

វណ្ណៈ	ចឹងក្រោយមកតាសុន សេន ស្លាប់នោះមានបានដឹងទេ?

ស្រួយៈ	បាទ! ស្លាប់គ្រាន់ដឹងថាស្លាប់ តែខ្ញុំនៅអូរស្វាយនេះដែរ ។

វណ្ណៈ	ចឹងពូមានដឹងថាហេតុអីបានជាគេសម្លាប់គ្នាឯងចឹងទេ?

ស្រួយៈ	ខ្ញុំអត់ដឹងដែរ ។

វណ្ណៈ	ចឹងដូចជាមានការតស៊ូជាមួយគ្នាហើយមានការសម្លាប់គ្នាទៀត?

ស្រួយៈ	ខ្ញុំអត់ដឹងដែរ ដឹងថា សុន សេន គេសម្លាប់ៗ មិនថាពីណាជាអកសម្លាប់អត់ដឹង ។

វណ្ណៈ	ចឹងក្រោយមកមានការចាប់តា០៦តា០៦ហ្នឹងដោយសាររឿងអីដែលទៅ?

ស្រួយៈ	អត់ដឹងដែលហ្នឹង ដឹងថាគេចាប់តែមិនដឹងថាគេចាប់រឿងអី តាម៉ុក ហ្នឹងហើយអ្នកចាប់ហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមិនខ្មែរក្រហមតស៊ូវាយយួនអីទាំងអស់គ្នា ក្រោយមកមានការបែកចែកខាងត្រពាំងប្រាសាទ ខាងតាម៉ុក ចោទថាចូលជាមួយខាងរដ្ឋាភិបាល ចឹងមានមែនដែលអត់ការនិយាយចឹង?

ស្រួយៈ កាលហ្នឹងពូសួរៗនិយាយចឹងឯង តាម៉ុក ប្រកាន់ខាង១០០៣-១០០១ កាលហ្នឹងពួកខ្ញុំខាង ១០០១តាម៉ុកខាង១០០៣ ។

វណ្ណៈ ចឹងអ្នកដែលបានដឹកនាំចូលជាមួយខាងរដ្ឋាភិបាលហ្នឹងពូមានដឹងថាពីណាគេទេ អ្នកនាំចូល?

ស្រួយៈ អ្នកនាំចូលមានតា លៀងហ្នឹងឯង ។

វណ្ណៈ ចឹងមានពីណាទៀត?

ស្រួយៈ ដឹងពីណាមានតែគាត់ហ្នឹងអ្នកដឹកនាំផ្តាច់ខ្លួនដំបូង ។

វណ្ណៈ ចឹងពូគេថា តាជុំ ជាតិ តាកែវ អី?

ស្រួយៈ បាទ!តាកែវ តាជុំ ជាតិ ហ្នឹងហើយ តាជុំ ជាតិ គេទៅមុន តាកែវ ទៅមុន តាលៀងគាត់ ដឹកនាំក្រោយ ។

វណ្ណៈ ចឹងពេលដែលចូលជាមួយរដ្ឋាភិបាលហ្នឹងឆ្នាំណាពូ?

ស្រួយៈ ចូលឆ្នាំ៩៨ ។

វណ្ណៈ ចឹងពេលហ្នឹងមានសមាហរណ៍កម្មហើយ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយយើងបានធូរស្រាលលែងរត់លែងអីហើយពេលហ្នឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងនិយាយទៅបើពូធ្វើការប្រៀបធៀប កាលសម័យដេលមានសង្គ្រាមមកដល់ឥឡូវពូគិតថា ការរស់នៅពីមុនហើយឥឡូវមួយណាស្រួលជាង?

ស្រួយៈ មកឥឡូវនេះស្រួល ។

វណ្ណៈ ចឹងលែងភ័យខ្លាចគ្រាប់រំសេវអីទៀត?

ស្រួយៈ បាទ!លែងភ័យខ្លាចគ្រាប់រំសេវហើយ ពូសួរថាថៃចេះចុះម្តងៗហ្នឹងក៏យចង់ខ្លាប់ កាលឆ្នាំ ២០០៨ហ្នឹងមានបន្តិចបន្តួចហ្នឹង ខ្ញុំរត់ធ្លាក់ព្រៃស្អាកនោះ តែទៅបានបួនប្រាំថ្ងៃ ។

វណ្ណៈ ចឹងពេលដែលមានសមាហរណ៍កម្មហើយចឹងកូនចៅបានទៅរៀនទៅសូត្រអីចឹង?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងហើយពូមកនៅនេះឆ្នាំណាដែរ ចេញមកពីអូរស្វាយ?

ស្រួយៈ ខ្ញុំមកឆ្នាំ៩៨ហ្នឹង ។

វណ្ណៈ ចឹងឆ្នាំ៩៨ចេញមកនៅទួលប្រាសាទវិញ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងមកនៅហ្នឹងរហូតលែងផ្លាស់ទៅណាទៀតហើយ?

ស្រួយៈ បាទ! នៅហ្នឹងរហូតដល់សព្វថ្ងៃ ។

វណ្ណៈ ចឹងមានចម្ការមានដីស្រែនៅនេះ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងដីស្រែដីចម្ការរាល់ថ្ងៃហ្នឹងមានប៉ះពាល់ជាមួយក្រុមហ៊ុនគេទេ?

ស្រួយៈ អត់មានទេ ។

វណ្ណៈ ពូមានដីច្រើនហិចតាដែលមកនៅនេះ?

ស្រួយៈ មានដី៤ទៅ៥ហាត់ ។

វណ្ណៈ ចឹងកូនមានផ្សេងទៀតទៅ?

ស្រួយៈ អត់ទេ ទាំងកូនទាំងអីហ្នឹង ។

វណ្ណៈ ចឹងកូនពូរាល់ថ្ងៃមានគ្រួសារប៉ុន្មាននាក់ហើយ?

ស្រួយៈ មានគ្រួសារបួននាក់ ។

វណ្ណៈ ចឹងនៅសល់តែពីរទៀតទេ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងធូរហើយមានគ្រួសារអស់ហើយ?

ស្រួយៈ សើច... ។

វណ្ណៈ មានគ្រួសារហើយបែកផ្ទះហើយ?

ស្រួយៈ បែកខ្លះនៅនេះខ្លះ នោះផ្ទះកូនមួយ ។

វណ្ណៈ ចឹងគ្រួសារពូអត់មានបញ្ហាអីទេ ការរាប់អានកូនចៅល្អទេ អត់មានបញ្ហាទេ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងចពោះអ្នកជិតខាងពូមានទំនាក់ទំនងល្អដែលទេ?

ស្រួយៈ ជិតខាងអត់អីទេ ។

វណ្ណៈ ចឹងរាល់ថ្ងៃហ្នឹងមានវត្តច្រើនទេនៅក្នុងស្រុកភូមិយើងហ្នឹង?

ស្រួយៈ នៅក្នុងស្រុកមានវត្តបីបួនប្រាំវត្ត ។

វណ្ណៈ ចឹងពូមានធ្លាប់ទៅវត្តអីទេ?

ស្រួយៈ ធ្លាប់ទៅវត្ត ។

វណ្ណៈ ចឹងពូកាន់ព្រះពុទ្ធសាសនាដែលចឹង?

ស្រួយៈ បាទ ។

វណ្ណៈ អត់មានកាន់សាសនាអីផ្សេងទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈៈ យ៉ាងម៉េចបានជាពូចូលចិត្តសាសនាព្រះពុទ្ធ?

ស្រួយៈ សើច...មានម៉េច ។

វណ្ណៈៈ ចឹងពូគិតថា សាសនាព្រះពុទ្ធហ្នឹង ពូគិតថាសាសនាហ្នឹងមានសារសំខាន់សម្រាប់ពូទេ?

ស្រួយៈ បាទ!មានសារសំខាន់ដែលហ្នឹង ។

វណ្ណៈៈ ចឹងសាសនាណែនាំឲ្យយើងល្អឬមួយយ៉ាងម៉េចពូ តាមពូយល់?

ស្រួយៈ សាសនានាំឲ្យយើងល្អហ្នឹងហើយ ។

វណ្ណៈៈ ចឹងដូចជាទំលាមទំលាប់ប្រពៃណីយើងសព្វថ្ងៃហ្នឹង តើក្មេងៗយើងរាល់ថ្ងៃដូចការស្លៀកពាក់តាមរបៀបពីដើមដែលឬក៏ឡូយឆាយជាងសម័យមុន?

ស្រួយៈ ឥឡូវគេតាមសម័យយើង ។

វណ្ណៈៈ ចឹងកាលសម័យមុនសម័យសីហនុសម័យអី ការស្លៀកពាក់សម័យមុនយ៉ាងម៉េចដែលពូប្រពៃណី?

ស្រួយៈ ខ្ញុំនៅក្មេងៗដែលជំនាន់ហ្នឹងខ្ញុំមិនសូវដឹងទេ ។

វណ្ណៈៈ ចឹងមកដល់សម័យបីឆ្នាំ ការស្លៀកពាក់តាមប្រពៃណីមានទេកាលហ្នឹង?

ស្រួយៈ សម័យបីឆ្នាំស្លៀកពាក់តាមប្រពៃណីបានតើ តែក្រអត់មានក្រណាត់កាត់ ។

វណ្ណៈៈ តែកាលហ្នឹងគេឲ្យយើងស្លៀកពាក់ហូរប្រមូងអីទេ បានទេ?

ស្រួយៈ អត់ទេ អត់មានទេ ជំនាន់ហ្នឹងមិនមានហូរប្រមូងទេ ។

វណ្ណៈៈ មានអាវខ្មៅខោខ្មៅ?

ស្រួយៈ អត់ទេ ខោអាវគេបើកឲ្យក្រណាត់ពណ៌ធម្មតា ក្រណាត់ពណ៌ផ្កាឈូលផ្ទៃមេឃស្អីៗក្រណាត់ពណ៌ធម្មតាហ្នឹង ។

វណ្ណៈៈ ចឹង?

ស្រួយៈ បាទ ។

វណ្ណៈៈ តែនៅតាមសហករណ៍ភាគច្រើនគេឲ្យស្លៀកពាក់ខ្មៅទាំងអស់?

ស្រួយៈ អត់ទេ ។

វណ្ណៈៈ អត់ទេ ចង់និយាយជំនាន់បីឆ្នាំ មិនមែនជំនាន់ពូនៅក្នុងព្រៃនេះទេ អាហ្នឹងខ្មែរក្រហមមែនតែហ្នឹងរបៀបសេរីបន្តិចហើយ ខ្ញុំចង់និយាយរបបបីឆ្នាំរបបនៅសហករណ៍ កាលជំនាន់ហ្នឹងគេស្លៀកពាក់យ៉ាងម៉េចដែរ?

ស្រួយៈ កាលហ្នឹងភាគច្រើនខ្មៅហើយ ។

វណ្ណៈ៖ ចឹងខាងយោធាក៏ខ្មៅដែរ?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងបានគេហៅរបបកាលហ្នឹងថា របបខោខ្មៅអាវខ្មៅ?

ស្រួយៈ ហ្នឹងហើយ ។

វណ្ណៈ៖ ដល់មកឆ្នាំ៧៩ហើយមានការផ្លាស់ប្តូរហើយការស្លៀកពាក់ពណ៌អីក៏បានដែរ?

ស្រួយៈ បាទ ។

វណ្ណៈ៖ គ្រាន់យើងអត់មានសាសនាអត់មានវត្តមានអី?

ស្រួយៈ បាទ ។

វណ្ណៈ៖ តែនៅខាងក្នុងគេបានអនុវត្តសាសនាមានវត្ត មានបុណ្យ មានភ្លេងការតាមប្រពៃណីពីដើមវិញហើយ?

ស្រួយៈ បាទ ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃហ្នឹងកូនពូមានបានរៀនសូត្របានច្រើនទេ?

ស្រួយៈ រៀនសូត្របានបីបួននាក់ ។

វណ្ណៈ៖ ពូគិតថា ការរៀនសូត្របានខ្ពង់ខ្ពស់ហ្នឹង តើមានសារសំខាន់ដែលអត់?

ស្រួយៈ បើរៀនបានខ្ពង់ខ្ពស់វាមានសារសំខាន់ហ្នឹងណាស់ តែវារៀនមិនបានខ្ពស់ហ្នឹង វាគ្មានលុយកាក់ឲ្យវាទៅរៀន ដល់ពេលរៀនខ្ពស់បន្តិចទៅវាបេះតែទៅឆ្ងាយ ដូចនេះគ្មានលុយកាក់គ្មានអីឲ្យវាជិះទៅធ្វើដំណើរទៅរៀន ។

វណ្ណៈ៖ ចឹងពូកាលសម័យសង្គ្រាមពូមានធ្លាប់ឃើញគេចាប់ឈ្លើយសឹកមកធ្វើបាបអីទេ?

ស្រួយៈ អត់ដែលឃើញទេ ។

វណ្ណៈ៖ ចឹងនៅក្នុងសម័យបីឆ្នាំមានដែលឃើញគេចាប់មនុស្សដែលទេ?

ស្រួយៈ អត់ទេ!ឮស្សូរគេនិយាយថា ចាប់ខាងនេះចាប់ខាងនោះ ខាងខ្ញុំវាមិនដែលឃើញ ។

វណ្ណៈ៖ ចឹងពូមានបានដឹងថា ជំនាន់ហ្នឹងមានគេសម្លាប់មនុស្សពូមានដឹងទេ?

ស្រួយៈ អត់ទេ ។

វណ្ណៈ៖ ចឹងដឹងក្រោយ៧៩បានដឹងទេ?

ស្រួយៈ បាទ!ក្រោយ៧៩នេះហើយបានឮគេថា កន្លែងខ្លះសុទ្ធតែឆ្អឹងខ្មោចអី ។

វណ្ណៈ៖ ចឹងមកដល់សព្វថ្ងៃនេះក្នុងមួយឆ្នាំពូបានទៅលេងស្រុកកំណើតម្តងឬពូមិនបានទៅទេ?

ស្រួយៈ បីទៅបួនប្រាំឆ្នាំនោះខ្ញុំ ខ្ញុំ៥ទៅ៦ឆ្នាំហើយដឹង ។

វណ្ណៈ៖ ចឹងមកដល់ឥឡូវពូចង់ទៅរស់នៅស្រុកកំណើតវិញឬមួយមិនចង់ទេ?

ស្រួយៈ	ទេ ខ្ជិលទៅណាស់ បងប្អូនហៅឲ្យទៅនៅវិញដែលតែខ្ជិលទៅ ទៅណាបើនៅហ្នឹងដីចង្អៀតឲ្យដីធ្វើស្រែប្អូនទៅប្រាំអា១០អា២០អាចឹងទៅធ្វើយ៉ាងម៉េច នៅនេះម៉េចម្នាក់ក៏បានមួយហាត់ដែលចែកឲ្យកូន ។

វណ្ណៈ	នៅធ្វើមិនចង់រស់ទៀត?

ស្រួយៈ	បាទ! នៅនោះធ្វើរកស៊ីម៉េចបានហូប ។

វណ្ណៈ	ចឹងនៅហ្នឹងមានក្រុមហ៊ុននៅក្នុងស្រុកភូមិមានបង្កើតរោងចក្រអីនៅ?

ស្រួយៈ	អត់មានឃើញទេ ។

វណ្ណៈ	អត់ទាន់មានទេ?

ស្រួយៈ	បាទ ។

វណ្ណៈ	ចឹងបើសិនជាមានរោងចក្រកាត់ដេរអី ពូគិតថាអាចប្រជាជនរស់នៅសុចស្រួលទេ?

ស្រួយៈ	បើសិនជាមានរោងចក្រកាត់ដេរអីរស់នៅសុខស្រួលដែលហ្នឹង ខ្ញុំចង់ឲ្យកើតមានរោងចក្រដែលហ្នឹង ខ្ញុំចង់ឲ្យមានរោងចក្រហ្នឹង ។

វណ្ណៈ	ចឹងមកដល់រាល់ថ្ងៃហ្នឹងនៅក្នុងភូមិពូហ្នឹងមានកូនចៅទៅធ្វើការស្រុកថៃមានច្រើនទេ?

ស្រួយៈ	ទេ អត់មានផង ។

វណ្ណៈ	ចឹងសុខចិត្តនៅធ្វើចម្ការនៅនេះវិញ?

ស្រួយៈ	មានខ្លះទៅម៉ាឡេអីពីរឆ្នាំបីឆ្នាំអី ។

វណ្ណៈ	ចឹងមានអ្នកទៅម៉ាឡេវិញ?

ស្រួយៈ	បាទ ។

វណ្ណៈ	ចឹងអ្នកទៅហ្នឹងមកវិញធូរធារដែរ?

ស្រួយៈ	អ្នកអត់នៅតែអត់ដដែលហ្នឹង គ្មានអីធូរ ជិតផ្ទះប្រធានភូមិហ្នឹងកូនគេទៅម៉ាឡេ ។

វណ្ណៈ	ចឹងនៅក្នុងភូមិពូហ្នឹងមើលទៅប្រជាជនរស់នៅបានធូរដែលឬមួយជួបការលំបាកខ្លះដែរ?

ស្រួយៈ	ឃើ! អ្នកលំបាកៗដែលហ្នឹង អ្នកពិបាកៗអ្នកធូរធារ តែអ្នកលំបាកហ្នឹងមិនសូវឃើញធ្វើការងារអីផង ។

វណ្ណៈ	ចឹងពូផលដំណាំដែលយើងធ្វើបានហ្នឹងវាស្រួលលក់ទេ លក់ដូរដូចថាដំឡូងសណ្ដែកអីដែលយើងធ្វើបានហើយយកមកផ្ទះស្រួលលក់ទេ?

ស្រួយៈ	អាហ្នឹងស្រួលលក់ទេ ដំឡូងនិងសណ្ដែក ។

វណ្ណៈ	ចឹងឲ្យតែយើងធ្វើបាន?

ស្រួយៈ	បាទ! ឲ្យតែយើងធ្វើបានឡានគេចូលមកដល់ផ្ទះ ។

វណ្ណៈ ចឹងពូពេលដែលពូចង់ធ្វើស្រែចម្ការអីចឹងពូមានមានដែលពិភាក្សាជាមួយគ្រួសារថា ឆ្នាំនេះ យើងត្រូវធ្វើអី ឆ្នាំក្រោយត្រូវធ្វើអីពូមានដែលពិភាក្សាទេ?

ស្រួយៈ ដែរ ។

វណ្ណៈ ចឹងពិភាក្សាច្រើននៅពេលណា?

ស្រួយៈ តែវាគ្មានដីធ្វើចម្ការទៀត មានដីធ្វើស្រែ ដីចម្ការវាគ្មាន មានតែដីទំនាបរកដីទួលដាំដំឡូងមិនបាន ។

វណ្ណៈ ចឹងធ្វើស្រែបានច្រើនទេក្នុងមួយហិចតា?

ស្រួយៈ អត់សូវបានប៉ុន្មានទេ ក្នុងមួយហិចតាបានតែមួយតោនពីរតោនអីហ្នឹង ។

វណ្ណៈ ចឹងបានតិចដែរ?

ស្រួយៈ បាទ ។

វណ្ណៈ ចឹងយើងប្រើដីអស់ច្រើនទេ? .

ស្រួយៈ ខ្ញុំមិនដែលប្រើដីផង ប្រើខាងក្រោយតិចៗ ក្រៅពីហ្នឹងមិនដែលប្រើទេ ។

វណ្ណៈ ចឹងបើយើងមិនអាចប្រើដីបានល្អតែម្តង យើងហូបក៏ល្អ?

ស្រួយៈ បាទ!មិនសូវមានពីណាប្រើដីទេ នៅម្តុំភូមិនេះ ភាគតិចណាស់ប្រើដី ។

វណ្ណៈ ចឹងធ្វើសម្រាប់ទុកហូបខ្លួនឯងឬមួយយើងបានលក់ខ្លះដែរ?

ស្រួយៈ លក់អស់បាត់ហើយ ។

វណ្ណៈ លក់បានមួយគីឡូប៉ុន្មានស្រូវ?

ស្រួយៈ ១គីឡូបានតែ៨០០រៀល ។

វណ្ណៈ ចឹងថោកដែរ?

ស្រួយៈ បាទ!ឥឡូវឡើងបាន៨៥០រៀល ។

វណ្ណៈ តាមពិតបើបាន១០០០រៀលចំនិញ?

ស្រួយៈ បាទ!ហ្នឹងហើយបើបាន១០០០មានអី ចឹងបានថារបស់កសិករវាអត់ថ្លៃ ថ្លៃតែរបស់នាយទុន ។

វណ្ណៈ ចឹងមកដល់ឥឡូវពូមានស្គាល់គណៈស្រុកពាល់ថ្ងៃហ្នឹងទេ?

ស្រួយៈ គណៈស្រុកមិនស្គាល់ទេ ស្គាល់គណៈស្រុកចាស់ គណៈស្រុកឡើងថ្មីអត់ស្គាល់ទេ ។

វណ្ណៈ ចឹងចៅហ្វាយខេត្តមានស្គាល់ទេ?

ស្រួយៈ ចៅហ្វាយខេត្តតាសន នោះលែងហើយទៅឲ្យគេ គាត់លែងគាត់ដល់អាយុគាត់អាគ្រែតហើយ គេឲ្យអ្នកថ្មីមក ។

វណ្ណៈ៖ ចឹងពូផ្លូវនេះតាំងពីណាមក តាំងពីដើមមកប្ដូតាម៉ុកធ្វើដែរ?

ស្រួយៈ ផ្លូវនេះតាំងពីជំនាន់តាម៉ុក ធ្វើនេះ ។

វណ្ណៈ៖ ចឹងផ្ទះតាសារឿន ០៩នៅក្នុងបឹងនោះកន្លែងហ្នឹងជាកន្លែងប្រជុំឬមួយជាកន្លែងស្អី?

ស្រួយៈ គាត់ធ្វើផ្ទះទឹកគ្រាន់គាត់ប្រជុំម្ដងៗ ។

វណ្ណៈ៖ ឥឡូវកូនចៅគាត់មាននៅទេ តាសារឿន?

ស្រួយៈ ទេ កូនចៅគាត់នៅម្នាក់ពីរនាក់ទេ ។

វណ្ណៈ៖ កូនចៅគាត់ធូរធារដែលឬអត់ទេ?

ស្រួយៈ ទេ មិនឃើញធូរអីដែលទេ ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃហ្នឹងពូមានដែលទៅលេងផ្នូរតាម៉ុក ពូមានដើរទៅលេងទេ?

ស្រួយៈ អត់ស្គាល់ទេ មិនដឹងនៅកន្លែងណាផង ។

វណ្ណៈ៖ នៅជាំនៅត្រពាំងឈូក?

ស្រួយៈ សើច... ។

វណ្ណៈ៖ ផ្នូរតាម៉ុក ស្អាតណាស់គាត់ធ្វើអស់រាប់ម៉ឺនដុល្លា?

ស្រួយៈ ខ្ញុំមិនដែលស្គាល់ផង ។

វណ្ណៈ៖ ចឹងពូអត់ដែលទៅលេងខាងកាស៊ីណូអីទេ?

ស្រួយៈ អត់ទេ គ្រាន់តែអន្លង់វែងហ្នឹងបីទៅបួនឆ្នាំមិនទាន់ទៅអើតម្ដងផង ។

វណ្ណៈ៖ យ៉ាងម៉េចបានជាមិនបានទៅ?

ស្រួយៈ មិនដឹងថាទៅមានការអី ។

វណ្ណៈ៖ ចឹងយូរៗឡើងផ្សារម្ដងដែរ?

ស្រួយៈ ផ្សារឡើងបាន ។

វណ្ណៈ៖ គេហៅផ្សារអីហ្នឹង?

ស្រួយៈ ផ្សារទំនប់ដាច់ ។

វណ្ណៈ៖ ផ្សារទំនប់ដាច់មានរបស់របរច្រើនទេ?

ស្រួយៈ របរមិនសូវអត់ដែលហ្នឹងរបស់របរព្រោងព្រាតដែលហ្នឹង ។

វណ្ណៈ៖ ចឹងមួយអាទិត្យអីឡើងទៅញ៉ាំគុយទាវពីរដងដែរ?

ស្រួយៈ សើច...អត់ ។

វណ្ណៈ៖ មានម៉ូតូចចឹងជិះតែមួយភ្លេតដល់ហើយ?

ស្រួយៈ មួយភ្លេតដល់ហើយតែវាមិនសូវមានលុយដែរ ។

វណ្ណៈ	ចឹងនៅនេះមានខាងយុវជនស្ម័គ្រចិត្តគេមកវាស់វែងដីឲ្យដែរ?

ស្រួយៈ	នៅមិនទាន់ឃើញផង  មកខាងនោះៗឃើញមកវាស់អស់ហើយ ។

វណ្ណៈ	ចឹងបើសិនជាពូវាស់ទៅមានកម្មសិទ្ធពូសប្បាយចិត្តទេ?

ស្រួយៈ	សប្បាយចិត្តសប្បាយហើយតែដីវាមានតិច ។

វណ្ណៈ	តែបើសិនជាយើងមានប្លង់អី  អត់មានពីណាហ៊ានយករបស់យើងទៀតទេ?

ស្រួយៈ	បាទ ។

វណ្ណៈ	យើងផុតពីការទន្ទ្រានយកហើយ?

ស្រួយៈ	បាទ ។

វណ្ណៈ	ចឹងកាលភូមិនេះដំបូងសុទ្ធតែព្រៃធំៗមិនមែនទួលាយចឹងទេ?

ស្រួយៈ	សុទ្ធព្រៃឈើហ្នឹង  នៅនេះសុទ្ធឈើដើមប៉ុនៗនេះនោះ  គល់ប៉ុនៗនោះ ។

វណ្ណៈ	ចឹងគល់ធំៗណាស់ ។

ស្រួយៈ	បាទ ។

វណ្ណៈ	ឥឡូវកាប់អស់រលីង?

ស្រួយៈ	កាប់អស់ហើយតាមហ្នឹងអីសុទ្ធតែឈើច្រូងច្រាងហ្នឹង ។

វណ្ណៈ	គេថាតាម៉ុក  កាប់មួយចំនួនដែរ  កាប់លក់ឲ្យថៃ?

ស្រួយៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកយើងកាប់បន្តបន្ទាប់គ្នាចេះតែចែកគ្នាទៅ?

ស្រួយៈ	បាទ!ផ្លូវនេះសុទ្ធតែផ្លូវថៃដឹកឈើទេ ។

វណ្ណៈ	ផ្លូវហ្នឹង?

ស្រួយៈ	បាទ!តាម៉ុកធ្វើហើយបានថៃវាដឹកឈើ  វាមកធ្វើថែមទៀត ។

វណ្ណៈ	ចឹងកាលគេហៅតាម៉ុក  ទៅភ្នំពេញពូមានដឹងទេ?

ស្រួយៈ	អត់ទេ ។

វណ្ណៈ	គេចាប់តាម៉ុក  ពូអត់ដឹងដែរ  ក្រោយមកបានដឹងតាមទូរទស្សន៍ផ្សាយ?

ស្រួយៈ	បាទ!ក្រោយមកបានដឹង  គេនិយាយតៗហែរៗទៅបានដឹង ។

វណ្ណៈ	ដឹងថាតាម៉ុកគេចាប់?

ស្រួយៈ	បាទ ។

វណ្ណៈ	ពូមានដែលបានឃើញតាម៉ុកផ្ទាល់ទេ?

ស្រួយៈ	អត់ទេ  មិនដែលឃើញទេឮស្គរតែឈ្មោះ ។

វណ្ណៈ	ចឹងតាម៉ុក គាត់បានកសាងអីខ្លះពូមានដឹងទេ?

ស្រួយៈ	តាម៉ុក កសាងច្រើនដែលហ្នឹង ។

វណ្ណៈ	មានអីខ្លះទៅ?

ស្រួយៈ	កសាងផ្លូវ កសាងអីហ្នឹង ។

វណ្ណៈ	ចឹងបើតាមពីគិតថា តាម៉ុក គាត់ជាមនុស្សមួយយ៉ាងម៉េចដែរ ល្អឬអាក្រក់?

ស្រួយៈ	ពិបាកថាដែរ ។

វណ្ណៈ	ចឹងខ្ញុំដូចជាអស់អីសួរពូហើយ ពូមានអីបន្ថែមទៀតទេ?

ស្រួយៈ	គ្មានអីទេ ។

វណ្ណៈ	ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ស្រួយៈ	បាទ ។

**ចប់**